01369637

**Declassified to Public**
**05 April 2019**

E443/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 28 / 12 / 2016
ម៉ោង (Time/Heure): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ៖ | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Claudia FENZ** |
| | ចៅក្រម **យូរ ឧត្តរ** |
| កាលបរិច្ឆេទ៖ | ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៦ |
| ភាសាដើម៖ | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ៖ | សម្ងាត់ |

---

# ដីកាសម្រេចធ្វើការស៊ើបអង្កេតទៅលើឯកសារនានាដែលទទួលបានពីសាស្ត្រាចារ្យ WALTER HEYNOWSKI

---

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Nicolas KOUMJIAN

**<u>ជនជាប់ចោទ</u>**
នួន ជា
ខៀវ សំផន

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**
ពេជ អង្គ
Marie GUIRAUD

**<u>មេធាវីការពារក្តីជនជាប់ចោទ</u>**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងសូមរម្លឹកអំពីសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៦ ដែលអង្គជំនុំជម្រះបានកត់សម្គាល់ថា អង្គជំនុំជម្រះបានស្នើសុំព័ត៌មានពី Walter HEYNOWSKI (2-TCW-946) ទាក់ទិននឹងការដឹងរបស់គាត់អំពីឯកសារពាក់ព័ន្ធនានា ជំនួសឱ្យការស្តាប់សក្ខីកម្មរបស់គាត់[1]។ មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យសាស្ត្រាចារ្យ Walter HEYNOWSKI មកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងប្រធានបទស្តីពីមន្ទីរសន្តិសុខ ជាពិសេស មន្ទីរសន្តិសុខ ស-២១។ មេធាវីការពារក្តីបានលើកឡើងថា សាក្សីដែលបានស្នើសុំនេះបានផលិតភាពយន្តឯកសារមួយដែលបង្ហាញពីឯកសារច្បាប់ដើមដែលបានរកឃើញនៅមន្ទីរសន្តិសុខ ស-២១ ក្នុងឆ្នាំ ១៩៧៩ រួមទាំងកូនសៀវភៅពណ៌ទឹកក្រូចដែលចងក្រងកំណត់ត្រាប្រចាំថ្ងៃរបស់អ្នកជាប់ឃុំផងដែរ[2]។

២. នៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានរៀបចំវិធានការនានាដែលត្រូវអនុវត្តដើម្បីទទួលបានឯកសារដែលសាស្ត្រាចារ្យ Walter HEYNOWSKI មាន[3]។ ដោយសារតែការខិតខំប្រឹងប្រែងរបស់អង្គជំនុំជម្រះ សាស្ត្រាចារ្យ Walter HEYNOWSKI បានផ្តល់មកឱ្យអង្គជំនុំជម្រះនូវឯកសារជាច្រើនដែលមានប្រភពពីមន្ទីរសន្តិសុខ ស-២១ ជាពិសេស សៀវភៅពណ៌ទឹកក្រូចដែលចងក្រងកំណត់ត្រាប្រចាំថ្ងៃរបស់អ្នកជាប់ឃុំ ("សៀវភៅកំណត់ត្រាប្រចាំថ្ងៃរបស់អ្នកជាប់ឃុំ") និងសន្លឹកទំព័រមួយចំនួនដែលដាច់ចេញពីសៀវភៅនេះជាច្រើនសន្លឹកជាភាសាអាល្លឺម៉ង់ និងភាសាខ្មែរ ("ឯកសាររបស់ Walter Heynowski") ដែលមានសភាពចាស់ខ្លាំង[4]។ សៀវភៅកំណត់ត្រាប្រចាំថ្ងៃនៃអ្នកជាប់ឃុំត្រូវបានថតស្កេននិងបានដាក់ទៅក្នុងឃ្លាំងផ្ទុកឯកសាររួម (SMD)[5] ហើយភាគីបានទទួលការអនុញ្ញាតឱ្យចូលពិនិត្យមើលសៀវភៅកំណត់ត្រាប្រចាំថ្ងៃនៃអ្នក

---

[1] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា សុំឱ្យស្តាប់សក្ខីកម្មសាក្សីបន្ថែម អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E391, E392, E395, E412 និង E426) ឯកសារ E443 ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៦។

[2] សំណើលើកទីបួនរបស់ នួន ជា សុំស្តាប់សក្ខីកម្មសាក្សីសម្រាប់វគ្គមន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" ក្នុងសំណុំរឿង ០០២/០២ (ដំណើរការមន្ទីរសន្តិសុខ ស-២១ និងភស្តុតាងជាឯកសារ) ឯកសារ E412 ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦ កថាខណ្ឌ ៣១-៣២។

[3] ឯកសារដែលទទួលបានពីសាស្ត្រាចារ្យ Walter Heynowski ឯកសារ E443/2 ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦ ("អនុស្សរណៈជូនដំណឹង")។

[4] អនុស្សរណៈជូនដំណឹង កថាខណ្ឌ ៦។

[5] ERN 01355895-01356140

ជាប់ឃុំជាច្បាប់ដើមនេះ។ អង្គជំនុំជម្រះបានអញ្ជើញភាគីឱ្យពិនិត្យមើលសៀវភៅកំណត់ត្រាប្រចាំថ្ងៃនៃអ្នកជាប់ឃុំនេះ និងធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ហើយក្រោយមក សៀវភៅកំណត់ត្រាប្រចាំថ្ងៃនៃអ្នកជាប់ឃុំត្រូវបានទទួលយកជាឯកសារភស្តុតាង[6]។ ទោះជាយ៉ាងនេះក្ដី អង្គជំនុំជម្រះបានកត់សម្គាល់ផងដែរថា ឯកសាររបស់ Walter Heynowski មានសភាពចាស់ខ្លាំង ដែលអង្គភាពបណ្ណសាររបស់ អ.វ.ត.ក (RAU) មិនអាចយកប្រើប្រាស់ ដោយធានាថាមិនឱ្យមានការខូចខាតថែមទៀតនោះឡើយ។

៣. តាមបំណងរបស់សាស្ត្រាចារ្យ Walter Heynowski សៀវភៅកំណត់ត្រាប្រចាំថ្ងៃនៃអ្នកជាប់ឃុំ និង ឯកសាររបស់ Walter Heynowski នឹងត្រូវបរិច្ចាគដល់សារៈមន្ទីរទួលស្លែង[7]។ អង្គជំនុំជម្រះយល់ឃើញថា ត្រូវវាយតម្លៃទៅលើឯកសាររបស់ Walter Heynowski ទាំងនេះដើម្បីសម្រេចថាតើអាចយកឯកសារទាំងនេះមកថែរក្សា និងថតស្កែនបានដែរ ឬ ទេ។ ហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា ចាំបាច់ត្រូវស្នើសុំជំនួយពីប្រធានសារៈមន្ទីរទួលស្លែងលើបញ្ហាទាំងនេះ។

**តាមសំអាងហេតុដូចដែលបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

**សម្រេច** ធ្វើការស៊ើបអង្កេតបន្ថែម អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ដើម្បីទទួលបានសេចក្ដីបរិយាយមួយ រួមទាំងសំណៅថតស្កែន និងការវាយតម្លៃបឋមទៅលើលក្ខណៈពិសេស និងយថាភាពនៃឯកសាររបស់ Heynowski ប្រសិនបើអាច ដើម្បីធានាដល់ការថែរក្សាឯកសារទាំងនេះ ដើម្បីអាចយកមកប្រើប្រាស់ធ្វើជាឯកសារភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ បាន។

**ស្នើសុំ**ឱ្យប្រធានសារៈមន្ទីរទួលស្លែងពិនិត្យឯកសាររបស់ Walter Heynowski និងផ្ដល់ព័ត៌មានខាងក្រោមមកអង្គជំនុំជម្រះ ឱ្យបានត្រឹមថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ ៖

(១) សេចក្ដីបរិយាយលម្អិតនៃឯកសារនីមួយៗ រួមទាំង លក្ខណៈ និងចំណងជើង ចំនួនទំព័រ ភាសាដែលបានប្រើ លក្ខណៈនៃឯកសារ (វាយកុំព្យូទ័រ សរសេរដោយដៃ សរសេរចម្រុះ ។ល។) និងសភាពរបស់ឯកសារ។

---

6 សេចក្ដីសម្រេចលើសំណើសុំឱ្យទទួលយកកំណត់ត្រា និងសុំឱ្យកោះហៅសាក្សីចំនួនពីរនាក់ពាក់ព័ន្ធនឹង ស-២១ (សម្ងាត់) ឯកសារ E443/3 ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៦។

7 លិខិតផ្ញើជូនប្រធានសារៈមន្ទីរទួលស្លែង ទាក់ទិននឹង ការបរិច្ចាគឯកសារពីសាស្ត្រាចារ្យ Walter Heynowski និងការស្នើសុំព័ត៌មាន ឯកសារ E443/4 ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៦។

(២) ការបង្ហាញថា តើអាចថែរក្សា និងថតស្កេន/ថតជារូបភាព នូវឯកសារទាំងនេះបានដែរ ឬទេ។ ប្រសិនបើអាចធ្វើទៅបាន តើការថតស្កេន ឬ ថតជារូបភាពនូវឯកសារទាំងនេះ ត្រូវចំណាយពេលប៉ុន្មាន ទើបអាចប្រគល់ជូនមកអង្គជំនុំជម្រះសាលាដំបូងបាន។

(៣) ការវាយតម្លៃថា តើឯកសារទាំងនេះជាឯកសារថ្មីដែលមិនទាន់មាននៅក្នុងបណ្ណសារដ្ឋានរបស់ទួលស្លែង ឬ ក៏ជាឯកសារជាន់គ្នាទៅនឹងឯកសារដែលមានក្នុងបណ្ណសារដ្ឋាននៅទួលស្លែង ឬ បណ្ណសារដ្ឋានសាធារណៈផ្សេងទៀតរួចហើយ។ និង

(៤) ការវាយតម្លៃ *បឋម* អំពីយថាភាពនៃឯកសារជាភាសាខ្មែរ។

ភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៦

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C * C.E.T.C

និល ណុន